**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ព្រឹទ្ធសភា**
**អគ្គលេខាធិការដ្ឋាន**

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែកញ្ញា និងទិសដៅការងារខែតុលា ឆ្នាំ២០១៦

**សេចក្តីផ្តើម** :

នៅក្នុងខែកញ្ញានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំបំពេញការងារយ៉ាងសកម្ម និងមមាញឹកលើគ្រប់ការដ្ឋាន ដើម្បីផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនបានល្អប្រសើរតាមរយៈលទ្ធផលសំខាន់ៗដូចខាងក្រោមនេះ៖

## I.លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា:

### ១.មុខងារនីតិកម្ម:

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - ប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០១លើក និងប្រជុំពេញអង្គចំនួន០១លើក ដើម្បីពិនិត្យ និងសម្រេចលើសេចក្តីស្នើសុំលើកអភ័យឯកសិទ្ធិសភារបស់លោកជំទាវ ថាក់ ឡានី សមាជិកាព្រឹទ្ធសភា មណ្ឌលភូមិភាគទី២ ។ | - បានចាត់ចែងនីតិវិធី ឯកសារពាក់ព័ន្ធ ធ្វើកំណត់ហេតុសង្ខេប និងពិស្តារនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងប្រជុំពេញអង្គព្រឹទ្ធសភា<br>- រៀបចំសម្អាត តុបតែងសាល បម្រើភេសជ្ជៈ ផ្គត់ផ្គង់សម្ភារ និងអាហារសម្រន់សម្រាប់កិច្ចប្រជុំចំនួន០៦លើក មានអ្នកចូលរួមចំនួន៥១៧នាក់<br>- ថតចម្លងឯកសារ និងចងក្រងធ្វើជាសៀវភៅចំនួន ១៦សំណើ អស់ក្រដាសចំនួន២៣,៧៨៦សន្លឹក<br>- បានប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន ៧៧នាក់ ស្មើនឹង០៤លើក និងកម្លាំងអន្តរាគមន៍ពីខាងក្រៅស្ថាប័នមានចំនួន៦៥នាក់ ដើម្បីការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំ<br>- ប្រជុំក្រុមការងារបច្ចេកទេស ដើម្បីពិនិត្យសិក្សា |



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

| | |
|---|---|
| | ស្រាវជ្រាវ និងរៀបចំសេចក្ដីព្រាងបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភាថ្មី និងសេចក្ដីព្រាងក្រមសីលធម៌សមាជិកព្រឹទ្ធសភាសម្រាប់នីតិកាលទី៤<br>- បន្តធ្វើបច្ចុប្បន្នភាពប្រតិទិនសម័យប្រជុំព្រឹទ្ធសភា បញ្ជីច្បាប់ដែលព្រឹទ្ធសភាបានពិនិត្យ និងឲ្យយោបល់តាមឆ្នាំ និងនីតិកាល<br>- បាននឹងកំពុងបន្តសិក្សាស្រាវជ្រាវលើប្រធានបទសំខាន់ៗពាក់ព័ន្ធនឹងតម្រូវការចាំបាច់របស់ស្ថាប័នចំនួន០៤ច្បាប់<br>- បានស្រាវជ្រាវអំពីនីតិវិធីក្នុងការតាក់តែងច្បាប់របស់សភាប្រទេសទាំង១០ នៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍<br>- បានរៀបចំទីកន្លែងប្រជុំចំនួន០៤លើក ត្រួតពិនិត្យប្រព័ន្ធសំឡេង ម៉េក្រូហ្វូន កាមេរ៉ាវីដេអូសុវត្ថិភាពចំនួន០៥លើក ថត និងផ្សព្វផ្សាយព័ត៌មានសេចក្ដីជូនដំណឹង សេចក្ដីប្រកាសព័ត៌មានចំនួន១០២លើក បង្ហោះលើគេហទំព័រព្រឹទ្ធសភា និងផលិតជា Video online ចំនួន៣៣លើក ។ |

## ២.មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា:

| *របនាសម្ព័ន្ធនយោបាយ* | *របនាសម្ព័ន្ធរដ្ឋបាល* |
|---|---|
| - សមាជិក សមាជិកាព្រឹទ្ធសភាបាន៖<br>+ អញ្ជើញជួបសវនាការជាមួយរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីស្វែងយល់អំពីការអន្តរាគមន៍សង្គមកិច្ច ការជួយដល់ប្រជាជនក្រីក្រងាយរងគ្រោះ ជនចំណាកស្រុកដោយប្រថុយប្រថាន ជនរងគ្រោះមហន្តរាយ | - ថត និងផ្សព្វផ្សាយព័ត៌មានសកម្មភាពរបស់សមាជិក សមាជិកាព្រឹទ្ធសភា បើកកិច្ចប្រជុំស្ដីពីការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ស្ដាប់បទបង្ហាញ និងកិច្ចប្រជុំផ្សេងៗចំនួន១៤លើក<br>- រៀបចំបែបបទ ធ្វើកំណត់ហេតុ និងរបាយការណ៍នៃជំនួបសវនាការចំនួន០១លើក |

| | |
|---|---|
| ផ្សេងៗ ការដោះស្រាយបញ្ហាជនអនាថា ការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ជួយជនរងគ្រោះដោយអំពើជួញដូរ ការអនុវត្តនយោបាយជាតិចំពោះជនពិការ ការការពារលើកកម្ពស់សិទ្ធិសុខុមាលភាពជនពិការតាមអនុសញ្ញានៃអង្គការសហប្រជាជាតិស្តីពីជនពិការ និងការអនុវត្តច្បាប់ស្តីពីកិច្ចការពារលើកកម្ពស់ជនពិការ<br>+ អញ្ជើញចុះជួបពិភាក្សាការងារជាមួយអភិបាលស្រុក និងក្រុមប្រឹក្សាឃុំ ដើម្បីស្វែងយល់ពីដំណើរការអនុវត្តគោលនយោបាយវិមជ្ឈការ វិសហមជ្ឈការ គោលនយោបាយភូមិ ឃុំ មានសុវត្ថិភាពនៅខេត្តកណ្តាល<br>+ អញ្ជើញចុះបេសកកម្មតាមដានលទ្ធផល និងស្វែងយល់អំពីវឌ្ឍនភាពការងារក្រោយពីការរៀបចំវេទិកាថ្នាក់ស្រុក និងជួបពិភាក្សាជាមួយប្រធានក្រុមប្រឹក្សា អភិបាលស្រុក មេឃុំ និងជំទប់ទី១ នៅខេត្តរតនគិរី<br>+ អញ្ជើញចុះសិក្សាស្រាវជ្រាវប្រមូលព័ត៌មាននៅខេត្តកំពង់ស្ពឺ ខេត្តព្រះសីហនុ និងខេត្តកោះកុង ។ | - ផ្ញើលិខិតបេសកកម្មជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចុះទៅតាមដានលទ្ធផលការងារ និងសិក្សាស្រាវជ្រាវប្រមូលព័ត៌មាន ព្រមទាំងស្វែងយល់អំពីការអនុវត្តច្បាប់នៅតាមបណ្តាខេត្តនានាចំនួន ៣៦នាក់ ស្មើនឹង០៦ច្បាប់ ។ |

**៣.មុខងារតំណាង** :

| វចនាសម្ព័ន្ធនយោបាយ | វចនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - សកម្មភាពការងាររបស់ថ្នាក់ដឹកនាំព្រឹទ្ធសភាបាន៖<br>+ អញ្ជើញទស្សនកិច្ចតំបន់អភិរក្សស្ពានីយឡូស្ទ័ដែកបុរាណសន្ទុងប្រឡាយដូនណាង | - រៀបចំបែបបទ ផ្តល់សេវា អមដំណើរថ្នាក់ដឹកនាំសមាជិកព្រឹទ្ធសភា អញ្ជើញចុះមូលដ្ឋាន ចូលរួមក្នុងកិច្ចប្រជុំ និងជាអធិបតីភាព ក្នុងពិធីផ្សេងការផ្សេងៗសរុបចំនួន៣៥១លើក |

| | |
|---|---|
| ស្ថានីយបុរាណវិទ្យា នៅខេត្តព្រះវិហារ<br>+ អញ្ជើញចូលរួមក្នុងពិធីកាន់បិណ្ឌ នាំយកបច្ច័យ ទេយ្យទាន ទេយ្យវត្ថុ និងគ្រឿងបរិក្ខារផ្សេងៗ ទៅប្រគេនព្រះសង្ឃគង់ចាំព្រះវស្សា និងសម្រាប់កសាងព្រះវិហារថ្មី ព្រមទាំងបានជូនអំណោយមួយចំនួនដល់យាយជី តាជីចំនួន០៥វត្ត នៅរាជធានីភ្នំពេញ ខេត្តកំពត និងខេត្តតាកែវ<br>+ អញ្ជើញជួបសំណេះសំណាល សាកសួរសុខទុក្ខជាមួយបងប្អូនប្រជាពលរដ្ឋខ្មែរ និងខ្មែរអ៊ីស្លាម បងប្អូនប្រជាពលរដ្ឋប្រកបមុខរបរជាចុងភៅ ជាអ្នកជាក់ស៊ីក្លូ ជាភ្នាក់ងារ និងកម្មករស៊ីនទ្រី សមាជិកសមាគមមនុស្សចាស់ និវត្តន៍ជន មន្ត្រីអតីតយុទ្ធជន លោកនាយក នាយករងវិទ្យាល័យ សាស្ត្រាចារ្យ ក្រុមសិល្បករ ព្រមទាំងអាជ្ញាធរ សង្កាត់ ភូមិ ដើម្បីស្តាប់សភាពការណ៍ និងលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតសរុបចំនួន១៤លើក នៅរាជធានីភ្នំពេញ ខេត្តព្រះវិហារ ខេត្តកំពង់ចាម និងខេត្តកំពង់ធំ<br>+ អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភាចូលរួមគោរពវិញ្ញាណក្ខន្ធសព ឯកឧត្តម **មិន ឃិន** ទេសរដ្ឋមន្ត្រីទទួលបេសកកម្មពិសេស និងសពមហាឧបាសក **ម៉ៅ មួន** ព្រមទាំងរំលែកទុក្ខក្រុមគ្រួសារសព ចំនួន០៣គ្រួសារ នៅរាជធានីភ្នំពេញ<br>+ អញ្ជើញទៅចុះឈ្មោះបោះឆ្នោត និងជួប | - បានធ្វើកំណត់បង្ហាញ និងបញ្ជូនពាក្យបណ្តឹងទៅក្រសួង ខេត្ត និងស្ថាប័នពាក់ព័ន្ធចំនួន ០៥ករណី<br>- បានផ្តល់សេវារដ្ឋបាល ពិធីការ និងទំនាក់ទំនងសាធារណៈ ការចុះស្រាវជ្រាវព័ត៌មាន ការរៀបចំវេទិកា និងការចុះតាមដានលទ្ធផលក្រោយការរៀបចំវេទិកា ព្រមទាំងជួបសំណេះ សំណាលជាមួយប្រជាពលរដ្ឋនៅរាជធានីភ្នំពេញ ខេត្តព្រៃវែង ខេត្តរតនគិរី ខេត្តត្បូងឃ្មុំ ខេត្តពោធិ៍សាត់ ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ស្ពឺ ខេត្តព្រះសីហនុ និងខេត្តកោះកុង<br>- រៀបចំពិធីសូត្រមន្តសុំសេចក្តីសុខ សេចក្តីចម្រើន នៅព្រឹទ្ធសភា និងពិធីកាន់បិណ្ឌ បុណ្យភ្ជុំបិណ្ឌ ជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា<br>- បានចុះសួរសុខទុក្ខនិវត្តន៍ជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន០៤នាក់<br>- ធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៩៩នាក់ ស្មើនឹង២៤ច្បាប់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិកព្រឹទ្ធសភាចំនួន០៤នាក់ ស្មើនឹង០៤ច្បាប់<br>- ថតចម្លងឯកសារចំនួន១៤សំណើ អស់ក្រដាសចំនួន៣,៥៦៧សន្លឹក<br>- ផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកា និងមន្ត្រីរាជការអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាក្នុងរាជធានី និងតាមបណ្តាខេត្ត ក្រុងទាំង៨ភូមិភាគចំនួន២៦៥នាក់ ស្មើនឹង៤៩លើក |

| | |
|---|---|
| សំណេះសំណាលជាមួយប្រជាពលរដ្ឋ និងអបអរសាទរ ឧបត្ថម្ភថវិកាមួយចំនួនដល់សិស្សដែលប្រលងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិនិទ្ទេសA ចំនួន ១១នាក់ នៅខេត្តកំពត<br>+ អញ្ជើញចុះជួបពិភាក្សាការងារជាមួយអាជ្ញាធរស្រុកកោះធំ នៅខេត្តកណ្ដាល<br>+ អញ្ជើញពិនិត្យ និងឧបត្ថម្ភការជួសជុលផ្លូវមួយខ្សែប្រវែង៦គីឡូម៉ែត្រ នៅខេត្តពោធិ៍សាត់<br>+ អញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃ នៅខេត្តតាកែវ<br>+ អញ្ជើញចូលរួមពិធីបុណ្យខួបគម្រប់ ១០០ថ្ងៃ សពឯកឧត្តម សាយ ភូថង នៅព្រះរាជាណាចក្រថៃឡង់ដ៍<br>- សមាជិកព្រឹទ្ធសភា បានបើកកិច្ចប្រជុំ ចូលរួមវេទិកា សិក្ខាសាលា និងធ្វើបទបង្ហាញពាក់ព័ន្ធមុខងាររបស់ខ្លួន ព្រមទាំងចូលរួមក្នុងពិធីផ្សេងៗបានចំនួន២២លើក<br>- បានធ្វើបទបង្ហាញស្ដីពីរចនាសម្ព័ន្ធតួនាទីភារកិច្ចរបស់ព្រឹទ្ធសភា ជូនដល់គណៈប្រតិភូដឹកនាំវ័យក្មេងមកពីតំបន់អាស៊ី និងសហរដ្ឋអាមេរិកចំនួន១៨នាក់ ព្រមទាំងសាស្ត្រាចារ្យ និងនិស្សិតមកពីសាកលវិទ្យាល័យជាតិគ្រប់គ្រង និងសេដ្ឋកិច្ច ខេត្តបាត់ដំបងចំនួន ២៧នាក់<br>- ព្រឹទ្ធសភាបានចូលរួមអនុវត្តន៍វិធានការ | - ផ្តល់សេវាថវិកាជូនព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន០៩លើក<br>- ទទួលលិខិតចូលចំនួន៦៨៨ច្បាប់ និងបញ្ជូនលិខិតចេញចំនួន៧១ច្បាប់<br>- បានប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុង ដើម្បីការពារសន្តិសុខ សុវត្ថិភាព សណ្ដាប់ធ្នាប់ ក្នុងពិធីផ្សេងៗ ចំនួន១៥នាក់ ស្មើនឹង០៣លើក<br>- ផ្តល់រូបថតចំនួន១,៨៥០សន្លឹក និងអត្ថបទសារព័ត៌មានចំនួន១៥៥អត្ថបទ ជូនខុទ្ទកាល័យ និងអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- ទទួលមន្ត្រីរាជការ សិស្ស និស្សិត និងសាធារណជនចូលអានសៀវភៅចំនួន១៩៧នាក់ ធ្វើប័ណ្ណសមាជិកចំនួន១៨រូប ខ្ចីសៀវភៅចំនួន៦២ក្បាល និងសងវិញចំនួន៥៧ក្បាល<br>- សម្របសម្រួលទទួលដំណើរទស្សនកិច្ចសិក្សាចំនួន០២លើក របស់គណៈប្រតិភូដឹកនាំវ័យក្មេងមកពីតំបន់អាស៊ី និងសហរដ្ឋអាមេរិកចំនួន១៨នាក់ ព្រមទាំងសាស្ត្រាចារ្យ និងនិស្សិតមកពីសាកលវិទ្យាល័យជាតិគ្រប់គ្រង និងសេដ្ឋកិច្ចខេត្តបាត់ដំបងចំនួន២៧នាក់<br>- ទទួលឯកសារ សៀវភៅពីអង្គការ ស្ថានទូត ក្រសួងស្ថាប័ន គ្រឹះស្ថានអប់រំ សប្បុរសជន និងអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន ៥៥២ក្បាល ព្រឹត្តិបត្រចំនួន២៣០ក្បាល ទស្សនាវដ្ដីចំនួន៣៣ក្បាល និងកាសែតចំនួន០៥ច្បាប់<br>- ផ្សព្វផ្សាយព័ត៌មានសង្ខេប និងព្រឹត្តិបត្រទស្សនព័ត៌មានប្រចាំថ្ងៃចំនួន៥៤ច្បាប់ ។ |

| | |
|---|---|
| ជួយសង្គ្រោះកសិករលើតម្លៃអង្ករ និងស្រូវ ព្រមទាំងផ្តល់អង្ករជូនមន្ត្រី និងបុគ្គលិក ធ្វើបុណ្យភ្ជុំបិណ្ឌម្នាក់មួយបាវគ្រប់ៗគ្នា<br>- ព្រឹទ្ធសភាបានទទួលពាក្យបណ្តឹងចំនួន ០៨ករណី ធ្វើកំណត់បង្ហាញពាក្យបណ្តឹងចំនួន០៥ករណី ធ្វើលិខិតអន្តរាគមន៍ផ្ញើជូនទៅស្ថាប័នមានសមត្ថកិច្ច ដើម្បីដោះស្រាយបានចំនួន០៥ករណី ទទួលលិខិតឆ្លើយតបពីការដោះស្រាយពាក្យបណ្តឹងពីស្ថាប័នមានសមត្ថកិច្ចបានចំនួន០៥ករណី និងឆ្លើយតបទៅម្ចាស់បណ្តឹងបានចំនួន០៥ករណី ព្រមទាំងទទួលពាក្យបណ្តឹងជូនជ្រាបចំនួន ០៣ករណី<br>- ព្រឹទ្ធសភាបានទទួលលិខិតពីរដ្ឋសភាចំនួន ០១ច្បាប់ និងពីក្រសួងស្ថាប័នពាក់ព័ន្ធចំនួន ៥២ច្បាប់<br>- សមាជិក សមាជិកាព្រឹទ្ធសភា បានចុះទៅតាមបណ្តាខេត្ត រាជធានី ទូទាំងប្រទេស ចំនួន២៣៣លើក ដើម្បីចុះជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ពិសេសផ្សព្វផ្សាយ និងជំរុញប្រជាពលរដ្ឋទៅចុះឈ្មោះបោះឆ្នោត និងការធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរគំរូថ្មី ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យព្យាបាលជំងឺប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ | |

| | |
|---|---|
| នៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ស្វែងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន៦៦លើក ។ | |

## ៤.មុខងារសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងសាធារណៈ :

| រចនាសម្ព័ន្ធនយោបាយ | រចនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា អនុញ្ញាតឲ្យឯកអគ្គរដ្ឋទូតអូស្ត្រាលី ឯកអគ្គរាជទូតជប៉ុន ប្រធានរដ្ឋសភាវៀតណាម គណៈប្រតិភូយុវជនអាស៊ាន ក្រុមហ៊ុនសៀងហៃ ស្ត្រីងអ៊ែរឡាញ និងប្រធានសមាគមជប៉ុន-កម្ពុជា ចូលជួបសម្តែងការគួរសម និងសវនាការចំនួន០៦លើក<br>- ប្រធានគណៈកម្មការទី៧ និងទី១០ អញ្ជើញចូលរួមប្រជុំក្រុមប្រឹក្សាប្រតិបត្តិលើកទី១ និងលើកទី២ ត្រៀមមហាសន្និបាតលើកទី៩ នៃសភាតំបន់អាស៊ី( APA ) នៅរដ្ឋសភា<br>- ក្រុមការងារសហប្រតិបត្តិការព្រឹទ្ធសភាកម្ពុជា បានអញ្ជើញប្រជុំ ដើម្បីផ្សព្វផ្សាយសេចក្តីសម្រេចស្តីពីការចាត់តាំងក្រុមការងារសហប្រតិបត្តិការព្រឹទ្ធសភាកម្ពុជា ជាមួយនឹងសភាបណ្តាប្រទេសនានា<br>- សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញទៅទស្សនកិច្ចសិក្សាស្វែងយល់នៅប្រទេសថៃ | - បានរៀបចំពិធីបដិសណ្ឋារកិច្ច ដំណើរទស្សនកិច្ចផ្លូវការរបស់គណៈប្រតិភូអន្តរជាតិ ឥស្សរជននយោបាយ អង្គទូត និងអង្គការអន្តរជាតិនានា<br>- រៀបចំសម្អាត តុបតែងសាល ផ្តល់សេវាផ្គត់ផ្គង់សម្ភារ ភេសជ្ជៈ និងអាហារសម្រន់ក្នុងពិធីផ្សេងៗចំនួន០៦លើក អ្នកចូលរួមចំនួន១០៨នាក់<br>- ថតចម្លងឯកសារចំនួន០២សំណើ អស់ក្រដាសចំនួន២៨សន្លឹក<br>- ផ្តល់សេវាថវិកា សម្ភារ និងភេសជ្ជៈ សម្រាប់ថ្នាក់ដឹកនាំ និងមន្ត្រីព្រឹទ្ធសភា ព្រមទាំងបានទូទាត់ថ្លៃចំណាយផ្សេងៗចំនួន១៩លើក<br>- ផ្តល់សេវាដឹកជញ្ជូនជូនមន្ត្រីរាជការព្រឹទ្ធសភាក្នុងរាជធានីចំនួន១៩នាក់ ស្មើនឹង១០លើក<br>- ទំនាក់ទំនងជាមួយស្ថានទូតបណ្តាប្រទេសជាមិត្ត ដើម្បីសម្រួលបែបបទ និងកម្មវិធីទស្សនកិច្ច ធ្វើកំណត់បង្ហាញ កំណត់ហេតុ កំណត់ទូត និងជំនួយស្មារតី រៀបចំបែបបទបើកបន្ទប់ពិសេស (VIP) នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ |

| | |
|---|---|
| និងជប៉ុន ចូលរួមសិក្ខាសាលាអន្តរជាតិតំបន់ស្ដីពីការកសាងសមត្ថភាពសភា និងការអនុវត្តបន្ថែមទៀតនូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅសាធារណរដ្ឋប្រជាមានិតចិន និងចូលរួមមហាសន្និបាតអន្តរសភាអាស៊ាន AIPA លើកទី៣៧ នៅប្រទេសមីយ៉ាន់ម៉ា ។ | ជូន និងទទួលដំណើរបេសកកម្មសរុបចំនួន ២១លើក<br>- ចេញលិខិតបេសកកម្មជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន១៤នាក់ ស្មើនឹង០៥ច្បាប់ និងបញ្ជូនទៅក្រៅស្ថាប័នព្រឹទ្ធសភាចំនួន០៨ច្បាប់<br>- រៀបចំកញ្ចប់ថវិកាដំណើរបេសកកម្មជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា ទៅបំពេញបេសកកម្មក្រៅប្រទេសចំនួន០៦លើក<br>- ការពារសន្តិសុខ សុវត្ថិភាព រៀបចំសណ្ដាប់ធ្នាប់ដោយប្រើប្រាស់កម្លាំងសរុបចំនួន៦៧នាក់ ស្មើនឹង០៦លើក<br>- អគ្គលេខាធិការ បានអញ្ជើញដឹកនាំគណៈប្រតិភូអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ទៅបំពេញទស្សនកិច្ចផ្លូវការ និងចុះហត្ថលេខាលើ MOU សហប្រតិបត្តិការជាមួយព្រឹទ្ធសភានៅប្រទេសឥណ្ឌា និងអញ្ជើញចូលរួមមហាសន្និបាតសមាគមអគ្គលេខាធិការសភាប្រើប្រាស់ភាសាបារាំងនៅប្រទេសម៉ារ៉ុក<br>- ទំនាក់ទំនងជាមួយស្ថានទូតបារាំង សភាវ៉ាឡូនីព្រុចសែល ប៊ែលហ្ស៊ិក ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង សមាគមអគ្គលេខាធិការនិយាយភាសាបារាំង សង្គមស៊ីវិលក្រសួង និងស្ថាប័ននានា សម្រាប់ដំណើរទស្សនកិច្ច សិក្ខាសាលា និងបំពេញបេសកកម្មក្នុង និងក្រៅប្រទេស ស្នើសុំអាហារូបករណ៍ វគ្គបណ្ដុះបណ្ដាល និងការរៀបចំពិធីផ្សេងៗ ។ |

**៥.មុខងារអភិវឌ្ឍន៍ស្ថាប័ន** :

| រចនាសម្ព័ន្ធនយោបាយ | រចនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - ព្រឹទ្ធសភាកំពុងអនុវត្តន៍ការសាងសង់អគារខុទ្ទកាល័យថ្នាក់ដឹកនាំព្រឹទ្ធសភា ជាជំនួយពីរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតចិន<br>- សហប្រតិបត្តិការជាមួយដៃគូ ដើម្បីអភិវឌ្ឍន៍ធនធានមនុស្ស និងអភិវឌ្ឍន៍ស្ថាប័ន | - ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា បានពិនិត្យផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៤៧៨ច្បាប់<br>- បានពិនិត្យវាយតម្លៃការអនុវត្តផែនការប្រតិបត្តិប្រចាំនព្វមាស ឆ្នាំ២០១៦<br>+ការងារគ្រប់គ្រងបុគ្គលិក:<br>- បានធ្វើលិខិតបទដ្ឋានផ្សេងៗពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីរាជការសរុបចំនួន៤៨ច្បាប់<br>- ប្រជុំអន្តរគណៈកម្មការវិសោធនកម្មច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ<br>- ប្រជុំគណៈកម្មការរៀបចំ និងកែសម្រួលបទបញ្ជាផ្ទៃក្នុងរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- ប្រជុំអំពីការពង្រឹងវិន័យ និងបទបញ្ជាផ្ទៃក្នុងរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>+ការងារបណ្តុះបណ្តាលធនធានមនុស្ស:<br>- បណ្តុះបណ្តាលធនធានមនុស្សនៅក្នុង និងក្រៅប្រទេសសរុបចំនួន០៧វគ្គ មានសិក្ខាកាមចូលរួមចំនួន១៦៤នាក់ និងសិក្ខាសាលានៅក្រៅប្រទេសចំនួន០១លើក មានសិក្ខាកាមចូលរួមចំនួន០១នាក់<br>- បានបន្តអនុវត្តន៍កម្មវិធីកម្មសិក្សារបស់និស្សិតក្នុង និងក្រៅប្រទេស<br>- កសាងផែនការបណ្តុះបណ្តាល និងអភិវឌ្ឍន៍ធនធានមនុស្សនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភារយៈពេល០៥ឆ្នាំ (២០១៧-២០២១) |

| | |
|---|---|
| | +ចាត់ចែងការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ :<br>- រៀបចំផែនការយុទ្ធសាស្ត្រថវិកា៣ឆ្នាំរំកិលព្រឹទ្ធសភា (២០១៧-២០១៩) និងការពារគម្រោងថវិកាឆ្នាំ២០១៧ ក្នុងកម្រិតនយោបាយ<br>- ប្រជុំអំពីគម្រោងបែងចែកកញ្ចប់ថវិកាឆ្នាំ២០១៧ របស់ព្រឹទ្ធសភា<br>- បានរៀបចំរបាយការណ៍ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា អំពីគម្រោងថវិកាឆ្នាំ២០១៧ ក្រោយការពារថវិកាក្នុងកម្រិតនយោបាយ<br>- បានរៀបចំរបាយការណ៍ចំនួនមន្ត្រីក្របខ័ណ្ឌ និងបុគ្គលិកជាប់កិច្ចសន្យា របាយការណ៍ប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភបុណ្យភ្ជុំបិណ្ឌ ប្រាក់បំណាច់ និងប្រាក់វិភាជន៍ផ្សេងៗ និងរបាយការណ៍ចំណាយថវិកាធៀបអាណត្តិប្រចាំខែកញ្ញា ឆ្នាំ២០១៦ ផ្ញើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ទូទាត់ថ្លៃទិញសម្ភារ គ្រឿងអេឡិចត្រូនិចចំនួន ១៩លើក ថែទាំ និងជួសជុលរថយន្ត និងសម្ភារឧបករណ៍បច្ចេកទេសផ្សេងៗចំនួន០២លើក ជួសជុលកែលម្អសោភ័ណ្ឌភាពសួនច្បារ អគារសាលប្រជុំ ផ្លូវថ្នល់នៅក្នុងបរិវេណព្រឹទ្ធសភា ចំនួន១៧លើក និងទូទាត់ការបោះពុម្ពសៀវភៅ និងឯកសារផ្សេងៗចំនួន០៧ក្បាល<br>- បានលើកគម្រោងទិញវត្ថុអនុស្សាវរីយ គ្រឿងបរិក្ខារផ្សេងៗ និងអាហារសម្រន់សម្រាប់កិច្ចប្រជុំ និងសិក្ខាសាលាចំនួន២៧សំណើ ព្រមទាំងបានប្រគល់ និងទទួលសម្ភារផ្សេងៗចំនួន០៩សំណើ |

| | |
|---|---|
| | ផ្គត់ផ្គង់សម្ភារអនាម័យ ការិយាល័យ និងកេសជ្ជៈ ចំនួន៣៧សំណើ ជូនគ្រប់អង្គភាពចំណុះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- រៀបចំសម្អាត តុបតែងសាល និងផ្តល់សេវាបម្រើកេសជ្ជៈ ក្នុងពិធីផ្សេងៗចំនួន១៤លើក មានអ្នកចូលរួមចំនួន៤១៣នាក់<br>- បានឧបត្ថម្ភ និងទូទាត់ថ្លៃចំណាយផ្សេងៗចំនួន ៦១លើក<br>- ថតចម្លងឯកសារ និងរៀបចំចងក្រងធ្វើជាសៀវភៅចំនួន៤៦សំណើ អស់ក្រដាសចំនួន ១២,៨៧០សន្លឹក ព្រមទាំងផ្តល់សេវាដឹកជញ្ជូនក្នុងរាជធានីចំនួន១០៤នាក់ ស្មើនឹង៩២លើក<br>**+ការកសាង និងជួសជុលហេដ្ឋារចនាសម្ព័ន្ធរូបវន្តរឹង និងទន់:**<br>- តាមដានគម្រោងស្នើសុំសាងសង់អគារសាលប្រជុំពេញអង្គថ្មីបានចាប់ផ្តើមដំណើរការ<br>- ចាត់ចែងការដ្ឋានចិន និងប្លង់អគារសាលប្រជុំពេញអង្គចាស់ និងថ្មី<br>- ការងារទិន្នន័យ និងប្លង់: អនុវត្តន៍គម្រោងពាក់ព័ន្ធអគារក្រហម ចិញ្ចើមផ្លូវ កែលម្អសួនច្បារ បរិស្ថាន និងអនុវត្តន៍គម្រោងជួសជុលបន្ទប់ទឹក ( អគារក្រហម សាលសិក្ខាសាលា បណ្ណាល័យ និងសាលពិសេស VIP)<br>- ធ្វើរបងស័ង្កសីជុំវិញការដ្ឋានសាងសង់អគារខុទ្ទកាល័យថ្នាក់ដឹកនាំទាំងបី និងរៀបជញ្ជាំងថ្មភ្នំនៅខាងក្រោយសាលខាងជើង និងពី P1 ដល់ P3 និងរបងគ៨៩<br>- គាស់ថ្មដុស ខឿនចាស់ និងម៉ាប រៀបទុយោទឹក |

| | |
|---|---|
| | ក្រោមម៉ាប រៀបដាក់ខឿនម៉ាបថ្មី ដាក់ស៊ីហ្វុង បង្ហូរទឹក និងរៀបការ៉ូម៉ាបនៅបរិវេណអគារក្រហម ក្រោយសាលពិសេស និងខាងមុខអគារក្រុមប្រឹក្សាធម្មនុញ្ញ<br>- លាបថ្នាំរបងសំណាញ់ខាងមុខព្រឹទ្ធសភា និងរៀបខឿនថ្មលំអមសងខាងអគារក្រហម និងនៅសួនច្បារក្រោយអគារក្រហម ព្រមទាំងស្តារប្រព័ន្ធលូ និងដាក់លូថ្មីក្នុងបរិវេណការដ្ឋានសាងសង់អគារខុទ្ទកាល័យថ្នាក់ដឹកនាំ<br>- សហការចុះត្រួតពិនិត្យសត្វកណ្តៀរ នៅសាលប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ សាលប្រជុំពេញអង្គ និងការិយាល័យអគ្គលេខាធិការ<br>- ជួសជុល និងផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច ក្រណាត់ពូកកៅអីថ្មី សោទ្វារ អូតូទ្វារអាលុយមីញ៉ូមចំនួន១៣៣គ្រឿង បន្ទប់ទឹក និងបណ្តាញទឹកចំនួន១៥បន្ទប់/ខ្សែ<br>- បិទលេខកូដម៉ាស៊ីនព្រីនធ័រ ម៉ាស៊ីនត្រជាក់ ម៉ាស៊ីនបូមព្រំ ម៉ាស៊ីនបាញ់ទឹក កុំព្យូទ័រ ទូរទស្សន៍ ទូ និងធ្នើរដាក់សៀវភៅចំនួន១៧គ្រឿង<br>- សហការរៀបចំ និងប្រចាំការម៉ាស៊ីនភ្លើងនៅតាមសាលប្រជុំចំនួន១៤លើក<br>- ចុះត្រួតពិនិត្យ តាមដានប្រព័ន្ធNetwork Internet Connect Wifi និងជួសជុលម៉ាស៊ីនកុំព្យូទ័រ ដាក់កម្មវិធីកំចាត់មេរោគ Update Files Antivirus បញ្ចូលកម្មវិធី Unicode និងSet up កម្មវិធីសរុបចំនួន១២៤គ្រឿង។ រៀបចំមាតិកា និងUpload រូបភាពសកម្មភាពការងារសំខាន់ៗរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា លើគេហទំព័រព្រឹទ្ធសភាសរុបចំនួន២៣០ប្រធានបទ |

| | |
|---|---|
| | +ការងារផ្សេងៗ:<br>- រៀបចំ និងចងក្រងសៀវភៅជាភាសាអង់គ្លេស ច្បាប់ កាសែត ទស្សនាវដ្ដី ព្រឹត្តិបត្រ រាជកិច្ច ដាក់លេខកូដសៀវភៅថ្មីសរុបចំនួន៩០ក្បាល បញ្ចូលសៀវភៅតាម PMB និងបញ្ចូលឯកសារសៀវភៅច្បាប់តាម E-Library សរុបចំនួន ១,០៧៨ក្បាល ដែលមានអ្នកចូលអានចំនួន ១,០៤៨នាក់ ។ |

II.**ទិសដៅការងារខែតុលា ឆ្នាំ២០១៦**

**១.មុខងារនីតិកម្ម**:

-ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងប្រជុំវិសាមញ្ញព្រឹទ្ធសភា (វិស្សមកាលថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៦) ៖

-សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈវិស័យសុខាភិបាល

-សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារទី៧ ស្តីពីប្រព័ន្ធឆ្លងកាត់គយនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីកិច្ចសម្រួលការដឹកជញ្ជូនឆ្លងកាត់ទំនិញ

-សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើ៖

+ កិច្ចព្រមព្រៀងស្តីពីការបង្កើត និងការអនុវត្តបញ្ជរតែមួយអាស៊ាន

+ ពិធីសារស្តីពីការបង្កើត និងការអនុវត្តបញ្ជរតែមួយអាស៊ាន

+ ពិធីសារស្តីពីក្របខ័ណ្ឌច្បាប់សម្រាប់អនុវត្តបញ្ជរតែមួយអាស៊ាន

-សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារ ដើម្បីអនុវត្តកញ្ចប់ទី៦ នៃការប្តេជ្ញាបើកចំហសេវាហិរញ្ញវត្ថុ នៅក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវា

-សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីការបង្កើតអង្គភាពស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ានបូក៣

-ត្រៀមបន្តនីតិវិធីពាក់ព័ន្ធច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា តាក់តែង និងពិគ្រោះយោបល់អំពីសេចក្តីព្រាងក្រមសីលធម៌ និងបទបញ្ជាផ្ទៃក្នុងថ្មី ។

**២.មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា** :

-ត្រៀមសម្រួលការជួបសវនាការរវាងគណៈកម្មការជំនាញ និងក្រសួងស្ថាប័ននានា និងការចុះបេសកកម្មតាមបណ្តាខេត្ត-ក្រុង ។

**៣.មុខងារតំណាង** :

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំព្រឹទ្ធសភា ចូលរួមក្នុងពិធីផ្លូវការនានា នៅតាមបណ្តាខេត្ត ក្រុង

-ត្រៀមរៀបចំវេទិកាតាមភូមិភាគ សិក្ខាសាលា និងពិធីសំណេះសំណាលផ្លូវការផ្សេងៗ

-ត្រៀមទទួលមន្ត្រីរាជការ យុវជន សិស្ស និស្សិត និងសាធារណជនមកទស្សនកិច្ចនៅព្រឹទ្ធសភា។

**៤.មុខងារសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងសាធារណៈ** :

-ត្រៀមរៀបចំពិធីជំនួបរវាងថ្នាក់ដឹកនាំជាមួយគណៈប្រតិភូបរទេស និងអង្គទូតនានា ជាពិសេសកម្មុងទស្សនកិច្ចនៃគណៈប្រតិភូជាន់ខ្ពស់ចិន ព្រមទាំងពិធីទទួលសារតាំងទូតថ្មី

-រៀបចំការបណ្តុះបណ្តាល PBO និងទំនាក់ទំនងលេខាធិការដ្ឋាន APF អំពីសហប្រតិបត្តិការបច្ចេកទេស

-សហប្រតិបត្តិការតំបន់ (ត្បូង ត្បូង) តាមរយៈកម្មវិធីបណ្តុះបណ្តាលខាងការស្រាវជ្រាវ(ជំហានទី២)

-ត្រៀមរៀបចំបែបបទជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា ព្រមទាំងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស

+ ចូលរួមមហាសន្និបាត( IPU ) និង( ASGP ) នៅប្រទេសស្វីស

-បន្តសកម្មភាពសហប្រតិបត្តិការការងារជាមួយដៃគូនានាៈ SES, CIM, KAS, GIZ, MARC PLAN FOUNDATION, UNESCO និង KOICA ។

**៥.មុខងារអភិវឌ្ឍន៍ស្ថាប័ន** :

- កសាងបូង់អគារសាលប្រជុំចាស់ ថ្មី និងការរៀបចំបរិវេណអគារថ្នាក់ការិយាល័យដឹកនាំ

-ការសិក្សារៀបចំ TV- online របស់ព្រឹទ្ធសភា និងបង្កើនការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងការងារប្រចាំថ្ងៃ

-ការចាប់ផ្តើមរៀបចំប្រព័ន្ធ Website/Webpage ក្នុងកម្រិតអគ្គនាយកដ្ឋាន និងគណៈកម្មការ

-បង្កើនសមត្ថភាពស្រាវជ្រាវលើគ្រប់វិស័យ ដើម្បីបង្កើនសមត្ថភាពផ្តល់សេវាព័ត៌មានចាំបាច់

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ តាមប្រព័ន្ធព័ត៌មានវិទ្យា កសាង Program និង Software ដើម្បីអនុវត្តន៍តាមអង្គភាព និងការបណ្តុះបណ្តាល ព្រមទាំងបានអនុវត្តកម្មវិធី E-បណ្ណាល័យ និងEបណ្ណសារ

-សិក្សាអំពីការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធតួនាទី និងភារកិច្ចរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បន្តកសាង និងធ្វើបច្ចុប្បន្នភាព គោលការណ៍គោលនយោបាយ លិខិតបទដ្ឋានគតិយុត្តិបម្រើឲ្យការគ្រប់គ្រងក្នុងបរិបទកំណែទម្រង់រដ្ឋបាលសាធារណៈ និងហិរញ្ញវត្ថុសាធារណៈ

-ត្រៀមកសាងប្រទីប ដើម្បីចូលរួមអបអរពិធីបុណ្យអុំទូក និងត្រៀមការបោះពុម្ពដំណាច់ឆ្នាំ

-បន្តអភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានតាមកិច្ចសហប្រតិបត្តិការជាមួយវៀតណាម ចិន កូរ៉េ

ជប៉ុន ឥណ្ឌា និងការបំពាក់សម្ភារបរិក្ខារប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានជំនួយរបស់សាធារណរដ្ឋសង្គមនិយមវៀតណាម (ដំណាក់កាលទី២)

-ជំរុញការស្នើសុំអាហារូបករណ៍ និងដាក់ពាក្យប្រលងអាហារូបករណ៍តាមប្រភពពីកូរ៉េ ជប៉ុន ចិន អូស្ត្រាលី នូវែលហ្សេឡង់ ឥណ្ឌា សិង្ហបុរី ម៉ាឡេស៊ី និងថៃ

-ការងារកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងការអនុវត្តជាក់ស្តែង

-ការរៀបចំថវិកាតាមកម្មវិធីឆ្នាំ២០១៧ សម្រាប់រចនាសម្ព័ន្ធនយោបាយ និងរដ្ឋបាល ។

## III.សេចក្តីសន្និដ្ឋាន

ក្នុងខែកញ្ញានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានចូលរួមរៀបចំពិធីកាន់បិណ្ឌ បុណ្យភ្ជុំបិណ្ឌ និងពិធីផ្សេងៗទៀតជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភាបានយ៉ាងល្អប្រសើរ ។ ជាមួយគ្នានេះ បានបំពេញការងារយ៉ាងសកម្មលើសេវាទ្រទ្រង់មុខងារនីតិកម្ម និងផ្តល់សេវាលើមុខងារផ្សេងទៀតជាអាទិ៍ៈ មុខងារតាមដានការអនុវត្តច្បាប់ និងមុខងារតំណាង ។ សកម្មភាពការងារប្រចាំថ្ងៃមានភាពមមាញឹក និងផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា បានដោយរលូន ។ ចំពោះមុខងារតាមដានការអនុវត្តច្បាប់ បានចាត់ចែងកម្មវិធីជួបសវនាការចំនួន០១លើក និងចុះតាមដានប្រមូលព័ត៌មាននៅខេត្តកណ្តាល ។ ដោយឡែកលើមុខងារតំណាង បានចាត់ចែងកម្មវិធីចុះជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋ ចៅសង្កាត់ មន្ត្រីភូមិ និវត្តន៍ជន ក្រុមសិល្បករចូលរួមគោរពវិញ្ញាណក្ខន្ធសព និងផ្សេងៗទៀត នៅរាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ ខេត្តកំពត ខេត្តតាកែវ ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តកំពង់ចាម ខេត្តបាត់ដំបង ខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យ ។ល។ ការអភិវឌ្ឍស្ថាប័នបានបន្តយកចិត្តទុកដាក់ខ្ពស់លើការអភិវឌ្ឍធនធានមនុស្ស និងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានថ្មីៗ ដើម្បីធានាបាននូវសេវាគ្រប់ប្រភេទប្រកបដោយគុណភាពខ្ពស់ជូនអតិថិជនរបស់ខ្លួន ។ ការងារកិច្ចសហប្រតិបត្តិការអន្តរជាតិ បានឆ្លុះបញ្ចាំងឲ្យឃើញនៅសូចនាករវិជ្ជមាននៃការគៀងគរដៃគូឧបត្ថម្ភគាំទ្រជំនួយពីគ្រប់មជ្ឈដ្ឋានជាតិ អន្តរជាតិសំដៅអភិវឌ្ឍន៍ធនធានមធ្យោបាយ និងហេដ្ឋារចនាសម្ព័ន្ធឲ្យកាន់តែសម្បូរបែបទំនើប និងទាន់ការវិវត្តឥតឈប់ឈរនៃបច្ចេកវិទ្យា រួមទាំងការរីកចម្រើនក្នុងតំបន់ និងពិភពលោក។៚

ភ្នំពេញ,ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៦

**អគ្គលេខាធិការ**

អ៊ុំ សារិទ្ធ